ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២៣ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

ក

មាតិកា

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

១៧-៦-១៩៩៦ ព្រះរាជក្រម ជស/រកម/០៦៩៦/០២ ច្បាប់ស្ដីពីការគ្រប់គ្រងឱសថ ៩៦៥

២ - ព្រះរាជក្រឹត្យ

២៧-៦-១៩៩៦ ព្រះរាជក្រឹត្យ NS/KRT/35 តែងតាំងមន្ត្រី ជាទីប្រឹក្សាផ្ទាល់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង ៩៧២

II - ទីស្ដីការគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

២០-៦-១៩៩៦ អនុក្រឹត្យលេខ២៧ អនក្រ.បក ស្ដីពីការបែងចែកជំពូកចំណាយឥតគ្រោងទុកនៃថវិការដ្ឋ ឆ្នាំ ១៩៩៦ ៩៧៤

២១-៦-១៩៩៦ អនុក្រឹត្យលេខ២៨ អនក្រ.បក ស្ដីពីបែបបទចំពោះការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា ៩៧៥

២១-៦-១៩៩៦ អនុក្រឹត្យលេខ ២៩ អនក្រ.បក ស្ដីពីថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ ប័ណ្ណស្នាក់នៅបណ្ដោះអាសន្ន និងប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍សំរាប់ជនបរទេសអន្តោប្រវេសន្ត ៩៨៦

២១-៦-១៩៩៦ អនុក្រឹត្យលេខ ៣០ អនក្រ.បក ស្ដីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតឱ្យជនបរទេសអន្តោប្រវេសន្តចេញ ចូល និងស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៩៨៨

២១-៦-១៩៩៦	អនុក្រឹត្យលេខ ៣១ អនក្រ.បក ស្ដីពីការប្ដូរឈ្មោះ «សាកលវិទ្យាល័យភ្នំពេញ» មកជា «សាកលវិទ្យាល័យភូមិន្ទភ្នំពេញ»	៩៩៤
១៧-៦-១៩៩៦	អនុក្រឹត្យលេខ ១១១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៩៥
១៧-៦-១៩៩៦	អនុក្រឹត្យលេខ ១១២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៩៧
១៧-៦-១៩៩៦	អនុក្រឹត្យលេខ ១១៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	៩៩៨
១៩-៦-១៩៩៦	អនុក្រឹត្យលេខ ១១៤ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	១០០០
១៩-៦-១៩៩៦	អនុក្រឹត្យលេខ ១១៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ	១០០១
២០-៦-១៩៩៦	អនុក្រឹត្យលេខ ១១៦ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ	១០០២

២ - សេចក្ដីសំរេច

១៧-៦-១៩៩៦	សេចក្ដីសំរេចលេខ ២២ សសរ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីដោះស្រាយប្រគល់បរិវេណប្ញីកីឡា មកឱ្យធ្វើការជួសជុល	១០០៣
២០-៦-១៩៩៦	សេចក្ដីសំរេចលេខ ២៣ សសរ ស្ដីពីការប្រគល់ភារកិច្ចបណ្ដោះអាសន្ន	១០០៦

III - ការងារបណ្ដាក្រសួង

១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សារាចរ

១៩-៦-១៩៩៦	សារាចរលេខ ០១១ សរ.សហវ.ហ ស្ដីអំពីកិច្ចប្រតិបត្តិការចំណូលថវិការដ្ឋ ឆ្នាំ ១៩៩៦	១០០៧
២០-៦-១៩៩៦	ប្រកាសលេខ ១៨៥ នបប្រក.សហវ ស្ដីពីការផ្ទេរភារកិច្ចភ្នាក់ងារគយ - រដ្ឋាករ	១០១៥

២ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

១៩-៦-១៩៩៦	ប្រកាសលេខ ៣៩៨ ផក.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុនយូណាធីត ហ្វែតហ្គាក មិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់សំរាប់នាំ ចេញ	១០១៩

៣ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

១៧-៦-១៩៩៦	ប្រកាសលេខ ០០២៩/៩៦ កព.ប្រក ស្តីពីការបង្កើតក្រុមជញ្ជូនឯកសាររបស់ក្រុមការងារពិសេស	១០២១
១៩-៦-១៩៩៦.	ប្រកាសលេខ ១៦៦/៩៦ ពម.បល.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១០២៣
១៩-៦-១៩៩៦	ប្រកាសលេខ ១៦៧/៩៦ ពម.បល.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១០២៤
១៩-៦-១៩៩៦	ប្រកាសលេខ ១៦៨/៩៦ ពម.បល.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ	១០២៥
២០-៦-១៩៩៦	ប្រកាសលេខ ១៧៨/៩៦ ពម.ប្រក អនុញ្ញាតជូនលោក យ៉ាំង យ៉ុងដាយ « Mr BAYON YOUNG DAL » សញ្ជាតិកូរ៉េ ប្រធានក្រុមហ៊ុន KORECAM IMEX CO.LTD បើកការិយាល័យប្រព័ន្ធផ្សព្វផ្សាយ	១០២៦

I - ខុទ្ទកាល័យព្រះមហាក្សត្រ

១ - ព្រះរាជក្រម

ព្រះរាជក្រម ជស/ រកម / ០៦៩៦ / ០២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.០៦ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល .
- បានឃើញព្រះរាជក្រមលេខ នស-រកម-០១៩៦-០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តី ពីការបង្កើតក្រសួងសុខាភិបាល

– តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីរដ្ឋមន្ត្រីក្រសួង សុខាភិបាល

ប្រកាសអោយប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងឱសថ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៦ នាសម័យប្រជុំលើកទី ៦ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ ÷

ច្បាប់

ស្តីពី

ការគ្រប់គ្រងឱសថ

ជំពូកទី ១

បទបញ្ញត្តិទូទៅ

មាត្រា ១ .-

ច្បាប់នេះមានគោលដៅគ្រប់គ្រងឱសថក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២ .-

ឱសថគឺជាសារជាតិមួយមុខ ឬច្រើនមុខដែលមានប្រភេទជាអាទិ៍ ពីជាតិគីមី ជីវផលិតផល ជាតិអតិសុខុមប្រាណ រុក្ខជាតិ លាយផ្សំឡើងសម្រាប់ :

– ប្រើប្រាស់ក្នុងការបង្ការ ឬព្យាបាលជម្ងឺមនុស្ស សត្វ
– ការស្រាវជ្រាវវេជ្ជសាស្ត្រ ឱសថសាស្ត្រ ឬធ្វើរោគវិនិច្ឆ័យ
– កែប្រែ ឬ ទ្រទ្រង់មុខងារនៃសរីរាង្គ ។

មាត្រា ៣ .-

ត្រូវបានចាត់ទុកជាឱសថដែរ :
១–សេរ៉ូម ឬ វ៉ាក់សាំង
២–ឈាម ឬផលិតផលដែលបានមកពីឈាម
៣–ឱសថបូរាណ
៤–ផលិតផលដែលផ្សំឡើងដោយមានជាតិពុលដែលមានក្នុងបញ្ជីកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៤ .-

អាចមានសិទ្ធិធ្វើផលិតកម្ម អាហរណនីហរណកម្ម និងពាណិជ្ជកម្ម ឱសថបានចំពោះឱសថការីដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមនេះ :
– មានសញ្ជាតិខ្មែរ
– មានសញ្ញាប័ត្រជាឱសថការីទទួលស្គាល់ដោយក្រសួងសុខាភិបាល
– មិនដែលមានទោសបទល្មើសព្រហ្មទណ្ឌណាមួយ
– មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារបាន ។

ចំពោះការផលិត អាហរណនីហរណកម្ម និងពាណិជ្ជកម្មឱសថបូរាណ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ២
ការគ្រប់គ្រងជាតិពុលសម្រាប់វិស័យសុខាភិបាល

មាត្រា ៥ .-

ជាតិពុលសំដៅលើឱសថ ឬសារជាតិ ឬសមាសធាតុនៃសារជាតិ ឬ រុក្ខជាតិដែលអាចបង្កអោយគ្រោះថ្នាក់ដល់សុខភាព ឬអោយញៀនដល់មនុស្សសត្វ។

ជាតិពុលនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ៦ .-

បែបបទនិងលក្ខខ័ណ្ឌក្នុងផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្ម ជាតិពុលត្រូវកំណត់ដោយអនុក្រឹត្យ ។

ជំពូកទី ៣

ផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មឱសថ

មាត្រា ៧ .-

បែបបទនិងលក្ខខ័ណ្ឌបច្ចេកទេសផលិតកម្មនិងការប្រព្រឹត្តិទៅនៃគ្រឹះស្ថានផលិតឱសថ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ត្រូវកំណត់ដោយប្រកាសរបស់ក្រសួង សុខាភិបាលនូវ :

- បែបបទ និងលក្ខខ័ណ្ឌក្នុងការសុំបើក ឬបិទ ឬប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ
- បែបបទនិងលក្ខខ័ណ្ឌក្នុងការសុំទិដ្ឋាការ បញ្ជីការឱសថ
- បែបបទនិងលក្ខខ័ណ្ឌបច្ចេកទេសគ្រប់គ្រងនិងថែរក្សាឱសថ
- បែបបទនិងលក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយឱសថ
- ព្រមទាំងបែបបទផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មឱសថ ។

ការកំណត់ចំនួនគ្រឹះស្ថានលក់ឱសថ ត្រូវធ្វើឡើងដោយក្រសួងសុខាភិបាល ដោយផ្អែកលើចំនួនប្រជាពលរដ្ឋក្នុងសង្កាត់ ឃុំ ជាមូលដ្ឋាន ។

មាត្រា ៨ .-

១-ត្រូវមានការអនុញ្ញាតពីក្រសួងសុខាភិបាលចំពោះ :

- ការបើក បិទ ឬប្តូរទីតាំងនៃគ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថ និងគ្រឹះ ស្ថានផលិតឱសថ
- ការធ្វើអាជីវកម្ម អាហរ័ណ នីហរ័ណកម្មឱសថ

– ការនាំចូល នាំចេញ ស្តុកឱសថ និងវត្ថុធាតុដើមសម្រាប់ផលិតឱសថ

– ការផ្សព្វផ្សាយឱសថ ។

២–ផលិតកម្ម អាហារ័ណ នីហារ័ណកម្មនិងពាណិជ្ជកម្មឱសថសម្រាប់ផ្នែកបសុពេទ្យ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងសុខាភិបាល និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

៣–ក្នុងគ្រឹះស្ថានលក់ឱសថត្រូវមានវត្តមានរបស់ឱសថការី ។ ក្នុងករណីអវត្តមានត្រូវមានអ្នកជំនួសដែលមានលក្ខណៈសម្បត្តិសមស្របកំណត់ ដោយក្រសួងសុខាភិបាល ។

ជំពូកទី ៤

សមត្ថកិច្ចក្នុងការគ្រប់គ្រង

មាត្រា ៩ .-

ការណែនាំ និងការត្រួតពិនិត្យដែលពាក់ព័ន្ធនឹងសកម្មភាពឱសថជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

ចំពោះការណែនាំ និង ការត្រួតពិនិត្យប្រភេទឱសថសម្រាប់ផ្នែកបសុព្យាបាលជាសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

ជំពូកទី ៥

ទោសបញ្ញត្តិ

មាត្រា ១០ .-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀល(មួយលានរៀល) ដល់ ១០.០០០.០០០ រៀល (ដប់លានរៀល) និងផ្អាកផលិតកម្មអាហារ័ណ នីហារ័ណកម្ម និងពាណិជ្ជកម្មឱសថពី ០១ ខែ ដល់ ០៣ ខែ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរខាងលើ ដោយពុំទាន់គិតដល់ការផ្តន្ទាទោស

ពីបទល្មើស ផ្សេងៗទៀតចំពោះបុគ្គលណាដែលបាន ÷

១–ផ្សព្វផ្សាយឱសថដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

២–ប្រព្រឹត្តល្មើសនឹងបែបបទ ឬល័ក្ខខ័ណ្ឌ ផលិតកម្ម អាហារ័ណនីហារ័ណកម្ម និង ពាណិជ្ជកម្មឱសថ ។

៣–បើក ឬប្តូរទីតាំង គ្រឹះស្ថានលក់ឱសថ គ្រឹះស្ថានផលិតឱសថ ឬធ្វើអាជីវកម្មអាហារ័ណ នីហារ័ណកម្មឱសថ ដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល ។

៤–ផលិត ឬនាំចូល ឬនាំចេញ ឬស្តុកឱសថ វត្ថុធាតុដើមឱសថ ដោយគ្មានការអនុញ្ញាត ពី ក្រសួងសុខាភិបាល ។

៥–លក់ឱសថគ្មានទិដ្ឋាការ ឬបញ្ជីការ ឬឱសថដែលក្រសួងសុខាភិបាលបានហាមឃាត់ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ និង ផ្អាក ផលិតកម្ម អាហារ័ណនីហារ័ណកម្ម និងពាណិជ្ជកម្មឱសថទ្វេឡើងមួយជាពីរ ឬទោសណាមួយក្នុងចំណោមទោសទាំងពីរខាងលើ ។

ឱសថ វត្ថុធាតុដើម សំភារៈ ឧបករណ៍ផ្សេងៗដែលទាក់ទង នឹងបទល្មើសដែលមានចែងក្នុង ចំណុច ៤ និង ៥ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល ។

ក្រសួងសុខាភិបាល មានសិទ្ធិផ្អាកជាបណ្តោះអាសន្នភ្លាមនូវ ការផ្សព្វផ្សាយឱសថ ផលិតកម្មអាហារ័ណនីហារ័ណកម្ម និងពាណិជ្ជកម្មឱសថដែលល្មើសរួចរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ។

មាត្រា ១១ .-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ រៀល (មួយលានរៀល) ដល់ ៥.០០០.០០០ រៀល (ប្រាំលានរៀល) ឬផ្តន្ទាទោសដាក់ ពន្ធនាគារពី ០៦ ថ្ងៃ ដល់ ០១ ខែ ឬទោសទាំងពីរនេះចំពោះជនណាដែលរារាំងមិនភ្នាក់ងារមានសមត្ថកិច្ចដែលមានចែងក្នុងមាត្រា ៩ ខាងលើបំពេញ ភារកិច្ច អធិការកិច្ចរបស់ខ្លួន ។

មាត្រា ១២ .-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ រៀល(ម្ភៃលានរៀល) ដល់ ៥០.០០០.០០០ រៀល (ហាសិបលានរៀល) ឬផ្តន្ទាទោស ដាក់ពន្ធនាគារពី ០៥ ឆ្នាំ ដល់ ១០ ឆ្នាំ ឬទោសទាំងពីរនេះ ចំពោះជន ណាដែលបានធ្វើផលិតកម្ម អាហរ័ណ នីហរ័ណកម្ម និងពាណិជ្ជកម្មដោយ ចេតនាឱសថមានសារជាតិញៀនដោយគ្មានការ អនុញ្ញាតឱសថក្លែងក្លាយ ឱសថគ្មានគុណភាព ឱសថហួសរយៈពេលប្រើ ដែលប៉ះពាល់ដល់សុខភាពអាយុជីវិតរបស់អ្នកប្រើប្រាស់ ។

មាត្រា ១៣ .-

ត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ១០,១១ និង ១២ ដែរ ចំពោះមន្ត្រីរាជការណាដែលឃុបឃិត ឬប្រព្រឹត្តរំលោភលើភារកិច្ចរបស់ខ្លួនក្នុងការអនុវត្តន៍មាត្រា ១០,១១ និង ១២ ។

ជំពូកទី ៦

អន្តរប្បញ្ញត្តិ

មាត្រា ១៤ .-

ក្រោយពេលច្បាប់នេះចូលជាធរមានរហូតដល់ឆ្នាំ២០០៥ ក្រសួងសុខាភិបាល មានសិទ្ធិចេញប្រកាសអនុញ្ញាតអោយមន្ត្រីសុខាភិបាលចូលនិវត្តន៍ដែលមានសមត្ថភាព បើកគ្រឹះស្ថានលក់ឱសថនៅតាមឃុំ សង្កាត់ណាដែលពុំទាន់មានគ្រឹះស្ថានលក់ឱសថ ត្រឹមត្រូវតាមការកំណត់ក្នុងមាត្រា ៤ និងមាត្រា ៧ នៃ ច្បាប់ នេះ ។

ជំពូកទី ៧

អវសានប្បញ្ញត្តិ

មាត្រា ១៥ .-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ក្នុងព្រះបរមនាម និង តាមព្រះរាជបញ្ជាដ៏ខ្ពង់ខ្ពស់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រីទី ១

ព្រះហស្តលេខា

នរោត្តម រណឫទ្ធិ

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា

ហ៊ុន សែន

បានបង្គំទូលថ្វាយ និង ជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រីទី ១ និង ទី ២

ជ-រដ្ឋមន្ត្រីក្រសួងសុខាភិបាល

ហត្ថលេខា

ឌី ណារ៉ុងរិទ្ធិ

* * *

២ - ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ NS / KRT - 35

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ។
- បានទ្រង់យល់ ព្រះរាជក្រឹត្យ NS/KRT/១១៩៤/០៨ ចុះថ្ងៃទី ០៨ ខែ

វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងឯកឧត្តម ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រី
ព្រះបរមរាជវាំងជាអ្នកឧកញ៉ាចៅហ្វាវាំង ។

– បានទ្រង់យល់ នូវការងារចាំបាច់ ។

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមន្ត្រីព្រះបរមរាជវាំង ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង ដែលមានឋានៈស្មើអនុរដ្ឋលេខាធិការដូចមានរាយនាមខាងក្រោមនេះ ÷

១-ឯកឧត្តម **ជុំ ចឿន**	ទទួលបន្ទុកការងារវប្បធម៌ - អភិរក្ស - ជួសជុល និង សំណង់
២-ឯកឧត្តម **គុយ សុផល**	ទទួលបន្ទុកការងារទំនាក់ទំនង - ពិធីការ និងគណនេយ្យ
៣-ឯកឧត្តម **មាឃ សំតួន**	ទទួលបន្ទុកការងាររដ្ឋបាល - យានដ្ឋាន និងកងរក្សាព្រះអង្គ
៤-ឯកឧត្តម **អ៊ុំ ឯម**	ទទួលបន្ទុកការងារសង្គមកិច្ច និង អន្តរាគមន៍សង្គ្រោះប្រជារាស្ត្រក្រីក្រ

មាត្រា ២ : នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាល និង ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីពេលឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦

ព្រះហស្តលេខា

នរោត្តម សីហនុ

* * *

II - ឯកសារគណៈរដ្ឋមន្ត្រី

១ - អនុក្រឹត្យ

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៧ អនក្រ.បក

ស្តីពីការបែងចែកជំពូកចំណាយឥត

គ្រោងទុកនៃថវិការដ្ឋឆ្នាំ ១៩៩៦

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៨៦ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៨៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្រ្តី និងជារដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : អនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋ ចំនួន ៣៨៣.៥០០.០០០,០០ រៀល (បីរយប៉ែតសិបបីលានប្រាំរយពាន់រៀលគត់) បញ្ចូលទៅ ជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច) របស់ក្រសួងផែនការ ។

មាត្រា ២ : សហរដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្រ្តីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្រ្តីទី ១	នាយករដ្ឋមន្រ្តីទី ២
ព្រះហស្តលេខ និង ត្រា	ហត្ថលេខ និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៨៦

អនុក្រឹត្យលេខ ២៨ អនក្រ.បក

ស្តីពី

បែបបទសំរាប់អនុវត្តចំពោះ ការអនុញ្ញាតអោយជនបរទេស មិនមែនអន្តោប្រវេសន្ត ចេញ ចូល និង ស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

សំរេច

ជំពូកទី១

បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះ កំណត់អំពីបែបបទសំរាប់ការចេញ ចូល និងការស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា នៃជនបរទេសមិនមែនអន្តោប្រវេសន្តដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ លើកលែងតែជនបរទេសរស់នៅតាមតំបន់ព្រំប្រទល់ជាប់ នឹងខេត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មវត្ថុ នៃអនុក្រឹត្យដោយឡែក ។

ជំពូកទី២

បែបបទសំរាប់ការចេញ ចូល ព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ : ជនបរទេស មិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលមានបំណងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈអាជ្ញាធរទូត ឬកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬតាមរយៈអាជ្ញាធរបរទេសណាមួយ ដែលតំណាងអោយផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។

តែចំពោះអ្នកទេសចរ យានិក នាវិក អ្នកដំណើរឆ្លងកាត់ អាចធ្វើពាក្យសុំនៅនឹងចំណុចច្រកទ្វារអន្តរជាតិណាមួយដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ជនបរទេសដូចមានចែងខាងលើ ត្រូវបំពេញបែបបទដូចតទៅ ÷

១-ត្រូវបំពេញបែបបទសុំទិដ្ឋាការ ។

២-បង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬ ឯកសារណាមួយ មានតម្លៃស្មើគ្នា និង ដែលមានសុពលភាពយ៉ាងតិច ៦ ខែ មុនថ្ងៃចូលព្រះរាជាណាចក្រកម្ពុជា ។

៣-ផ្តល់រូបថត ៤ × ៦ ចំនួនពាសន្លឹក « ថតចំពីមុខគ្មានពាក់មួក ឬ វ៉ែនតាពណ៌ » ។

៤-ត្រូវបង់ថ្លៃអាករទិដ្ឋាការ តាមការកំណត់ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ទោះក្នុងករណីទិដ្ឋាការនោះបានត្រូវបដិសេធក៏ដោយ ។

កុមារអាយុ ១២ ឆ្នាំ ចុះធ្វើដំណើរជាមួយឪពុក ម្តាយឬអាណាព្យាបាល មិនចាំបាច់បំពេញបែបបទដោយឡែកទេ តែត្រូវចុះឈ្មោះរួមជាមួយឪពុក ម្តាយ ឬអាណាព្យាបាលរបស់ខ្លួន ។

ជំពូកទី៣

ប្រភេទទិដ្ឋាការ រយៈពេល និង ថ្លៃទិដ្ឋាការ

មាត្រា ៣ : ទិដ្ឋាការ អាចជាទិដ្ឋាការប្រើសំរាប់ចេញ ចូល តែម្តងគត់ ឬ ច្រើនដង ។ ប្រភេទនៃទិដ្ឋា ការមានដូចខាងក្រោមនេះ ÷

១- ទិដ្ឋាការ ទូត កំណត់សំគាល់ដោយអក្សរធំ (A) ។ ទិដ្ឋាការនេះសំរាប់ផ្តល់អោយចំពោះ ជនបរទេសមិនមែនអន្តោប្រវេសន្ត និង ក្រុមគ្រួសាររបស់គេ កាន់លិខិតឆ្លងដែនការទូតហើយមក បំពេញបេសកកម្មការទូតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអាចត្រូវបានផ្តល់ជូនជនបរទេសដទៃទៀត ដែលមានការសំរេចពីរាជរដ្ឋាភិបាល ។

២-ទិដ្ឋាការផ្លូវការ កំណត់សំគាល់ដោយអក្សរធំ (B) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេដែលមកបំពេញបេសកកម្មក្នុងក្របខ័ណ្ឌរដ្ឋ អង្គការអន្តរជាតិនានា ដែលមានការទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៣-ទិដ្ឋាការចៅរីភាព កំណត់សំគាល់ដោយអក្សរធំ (C) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូន ជនបរទេសមិនមែនអន្តោប្រវេសន្តព្រមទាំងក្រុមគ្រួសាររបស់គេដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងនានា ចាត់ទុកថាជាការសំដែងនូវ ការគួរសម ។

៤–ទិដ្ឋាការកិច្ចការពាណិជ្ជកម្ម កំណត់ដោយអក្សរធំ(D)។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាអ្នកតំណាងពាណិជ្ជកម្ម ធនាគារឬ

ជាជនដែលមានមុខជំនាញវិជ្ជាជីវៈផ្សេង ៗ ដែលចូលមកក្នុងគោលបំណងធ្វើទំនាក់ទំនងក្នុងកិច្ចការជំនាញ ឬ សិក្សាស្រាវជ្រាវក្នុងក្របខ័ណ្ឌវិនិយោគ ។

៥- ទិដ្ឋាការកំណត់ដោយអក្សរធំ (E) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសារ ដែលមានបំណងចូលមកព្រះរាជាណាចក្រកម្ពុជា ដើម្បីសួរសុខទុក្ខសាច់ញាតិ និង មិត្តភក្តិ ឬដែលត្រូវគេអញ្ជើញអោយមកចូលរួមនៅក្នុងអង្គសិក្ខាសាលា សន្និសីទ ឬ នៅក្នុងពិធីផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦-ទិដ្ឋាការសារពត៌មាន កំណត់សំគាល់ដោយអក្សរធំ (F)។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្តព្រមទាំងក្រុមគ្រួសាររបស់គេដែលជាអ្នកសារពត៌ អ្នកបោះផ្សាយ ព្រឹត្តិប័ត្រ អ្នកឆ្លើយឆ្លងពត៌មាន ក្រុមវិទ្យុ និង ទូរទស្សន៍ ។

៧-ទិដ្ឋាការសិក្សាស្រាវជ្រាវ និងកម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគកំណត់សំគាល់ដោយអក្សរធំ (G) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេស មិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេដែលចូលមក ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងកម្មសិក្សាឬមកបង្ហាត់បង្រៀនតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល ។

៨-ទិដ្ឋាការនិយោជិត កំណត់សំគាល់ដោយអក្សរធំ (H) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេដែលមកធ្វើការនៅតាមរោងចក្រ សហគ្រាសសិប្បកម្ម ឬការដ្ឋានផ្សេងៗដែលមានកិច្ចសន្យាការងារ ។

៩-ទិដ្ឋាការសាសនា និងកិច្ចការសង្គម កំណត់សំគាល់ដោយអក្សរធំ (I) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលចូលមកដើម្បីប្រាស្រ័យទាក់ទងខាងកិច្ចការសាសនា និងកិច្ចការសង្គមដូចជាមកសំដែងសិល្បៈតូរ្យតន្ត្រី ឬ កីឡា ឬ មកក្នុងឋានៈជាអង្គការក្រៅ

រដ្ឋាភិបាល ឬ សមាគមនានា ។

១០–ទិដ្ឋាការទេសចរណ៍ កំណត់សំគាល់ដោយអក្សរធំ (J) ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ ជូនជនបរទេសមិនមែនអន្តោប្រវេសន្តអ្នកទេសចរ ។

១១–ទិដ្ឋាការយានិក នាវិក និងឆ្លងកាត់កំណត់សំគាល់ដោយអក្សរធំ (K) ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលជាអ្នកបើកបរ បុគ្គលិក កម្មករនាវា ឬ យន្តហោះ ។

១២–ទិដ្ឋាការធម្មតា កំណត់សំគាល់ដោយអក្សរធំ (L) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ទាំងឡាយណាដែលគ្មានរាប់ចូលក្នុងប្រភេទណាមួយដូចខាងលើនេះ ។

មាត្រា ៤ : រយៈពេលអនុញ្ញាតអោយប្រើប្រាស់ទិដ្ឋាការគ្រប់ប្រភេទត្រូវកំណត់៣ ខែចាប់តាំងពីថ្ងៃចេញទិដ្ឋាការនោះ ។ ផុតរយៈពេល ៣ ខែនេះត្រូវសុំទិដ្ឋាការថ្មី ។ រយៈពេលស្នាក់នៅ ដែលត្រូវបានអនុញ្ញាតជនបរទេសបានចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈទិដ្ឋាការដែលផ្តល់ដំបូងជាទូទៅអាចស្នាក់នៅ ១ ខែ ។ ប៉ុន្តែរយៈពេលស្នាក់នេះអាច អនុញ្ញាត ៦ ខែ ចំពោះទិដ្ឋាការទូត ឬផ្លូវការ ។ អាចស្នាក់នៅបាន ៧ ថ្ងៃចំពោះទិដ្ឋាការយានិក និង ឆ្លងកាត់ ។ ការបន្តរយៈពេលស្នាក់នៅត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យ នេះ ។

មាត្រា ៥ : មូលហេតុនៃការស្នាក់នៅជាក់ស្តែង ត្រូវតែស្របតាមប្រភេទនៃទិដ្ឋាការដែលចេញអោយ ។

មាត្រា ៦ : ថ្លៃអាករទិដ្ឋាការត្រូវកំណត់ដូចខាងក្រោម ÷

–ទិដ្ឋាការ ទូត	(A) 00៛,00
–ទិដ្ឋាការ ផ្លូវការ	(B) 00៛,00
–ទិដ្ឋាការ ចៅរីភាព	(C) 00៛,00
–ទិដ្ឋាការ កិច្ចការពាណិជ្ជកម្ម	(D) ៦0.000៛,00
–ទិដ្ឋាការ សួរសុខទុក្ខ	(E) ៦0.000៛,00

–ទិដ្ឋាការ សារពត៌មាន (F) ៦០.០០០៛,០០

–ទិដ្ឋាការ សិក្សាស្រាវជ្រាវ និងកម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគ

(G) ០០៛,០០

–ទិដ្ឋាការ និយោជិត (H) ៥០.០០០៛,០០

–ទិដ្ឋាការ សាសនានិងកិច្ចការសង្គម (I) ៥០.០០០៛,០០

–ទិដ្ឋាការ ទេសចរណ៍ (J) ៥០.០០០៛,០០

–ទិដ្ឋាការ យានិក នាវិក និង ឆ្លងកាត់ (K) ៥០.០០០៛,០០

–ទិដ្ឋាការ ធម្មតា (L) ៥០.០០០៛,០០

ថ្លៃអាករទិដ្ឋាការនេះអាចបង់ជារូបិយប័ណ្ណបរទេស ដែលមានតម្លៃស្មើគ្នានឹងថ្លៃ អាករទិដ្ឋាការជាប្រាក់រៀល ដែលកំណត់ខាងលើ ។

ជំពូកទី៤

ការចេញ ការពន្យារ និង ការបដិសេធទិដ្ឋាការ

មាត្រា ៧ : ទិដ្ឋាការអាចពន្យារបានដូចតទៅ ÷

– ចំពោះទិដ្ឋាការ ការទូត (A) អាចពន្យារបាន ១២ ខែ

– ចំពោះទិដ្ឋាការ ផ្លូវការ (B) អាចពន្យារបាន ១២ ខែ

– ចំពោះទិដ្ឋាការ ឋេរីភាព (C) អាចពន្យារបាន ៣ ខែ

– ចំពោះទិដ្ឋាការ កិច្ចការពាណិជ្ជកម្ម (D) អាចពន្យារបាន ៦ ខែ

– ចំពោះទិដ្ឋាការ សួរសុខទុក្ខ (E) អាចពន្យារបាន ៣ ខែ « បានតែម្តងគត់ »

– ចំពោះទិដ្ឋាការ សារពត៌មាន (F) អាចពន្យារបាន ៦ ខែ

– ចំពោះទិដ្ឋាការសិក្សាស្រាវជ្រាវនិងកម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគ (G) អាចពន្យារបាន ១២ ខែ

– ចំពោះទិដ្ឋាការ និយោជិត (H) អាចពន្យារបាន ១២ ខែ

- ចំពោះទិដ្ឋាការ សាសនា និងកិច្ចការសង្គម (I) អាចពន្យារបាន ៣ ខែ «បានតែម្តងគត់ »
- ចំពោះទិដ្ឋាការទេសចរណ៍ (J) អាចពន្យារបាន ៣ ខែ «បានតែម្តងគត់ »
- ចំពោះទិដ្ឋាការយានិក និងនាវិក ឆ្លងកាត់ (K) មិនអាចពន្យារបានទេ លើកលែងតែករណីប្រធានស័ក្តិ
- ចំពោះទិដ្ឋាការធម្មតា (L) អាចពន្យារបាន ៣ ខែ « បានតែម្តងគត់ »

មាត្រា ៨ : បែបបទនៃការពន្យារទិដ្ឋាការមានដូចតទៅ ÷

១-បំពេញពាក្យសុំពន្យារទិដ្ឋាការ

២-ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន ដែលនៅមានសុពលភាព លើសរយៈពេលស្នើសុំ ស្នាក់នៅ ៣ ខែ ។

៣-រូបថត ៤ × ៦ ចំនួន ០១ សន្លឹក ថតចំពីមុខ គ្មានពាក់មួក និង វ៉ែនតាពណ៌ ។

៤-ត្រូវបង់ថ្លៃអាករពន្យារទិដ្ឋាការតាមការកំណត់ក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

៥-អាចស្នើសុំពន្យារពេលស្នាក់នៅលើសពី ៦ខែ បានចំពោះតែទិដ្ឋាការណាដែលគ្មានចំណារថាពន្យារ «បានតែម្តងគត់ » ប៉ុន្តែត្រូវមានលិខិតបញ្ជាក់ដូចតទៅ ÷

- លិខិតអនុញ្ញាតអោយធ្វើពាណិជ្ជកម្ម ចេញអោយដោយក្រសួងមានសមត្ថកិច្ច ឬ
- លិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចណាមួយដែលខ្លួនមានទំនាក់ទំនងការងារជាមួយដោយបញ្ជាក់ថា «ពិតជាមានការចាំបាច់ដើម្បីបន្តទិដ្ឋាការមែន » ឬ
- កិច្ចសន្យាការងារជាមួយប្រធានរោងចក្រ សហគ្រាស សិប្បកម្ម ឬការដ្ឋានដែលទទួល ស្គាល់ដោយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

មាត្រា ៩ : អាជ្ញាធរទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬ ស្ថានតំណាងព្រះរាជាណាចក្រកម្ពុជានៅបរទេសមានសមត្ថកិច្ច ចេញទិដ្ឋាការគ្រប់ប្រភេទ ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ចចេញ ពន្យារ និង បដិសេធទិដ្ឋាការចំពោះប្រភេទទិដ្ឋាការ÷

-ទិដ្ឋាការ ទូត (A)

-ទិដ្ឋាការ ផ្លូវការ (B)

-ទិដ្ឋាការ សេរីភាព (C)

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចកិច្ចចេញ ពន្យារ និង បដិសេធទិដ្ឋាការចំពោះប្រភេទទិដ្ឋាការ ដទៃទៀត ។

មាត្រា ១០ : អាករលើការពន្យារទិដ្ឋាការ ត្រូវកំណត់ដូចខាងក្រោម ÷

១-៧៥.០០០៛,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ១ ខែ ។

២-១៥០.០០០៛,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ៣ ខែ ។

៣-២៥០.០០០៛,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ៦ ខែ ។

៤-៣៧៥.០០០៛,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ១២ ខែ ។

អាករលើការពន្យារពេលទិដ្ឋាការខាងលើនេះ មិនអនុវត្តលើការពន្យារទិដ្ឋាការចំពោះទិដ្ឋាការទូត ទិដ្ឋាការផ្លូវការ និងទិដ្ឋាការសេរីភាព និងទិដ្ឋាការសិក្សាស្រាវជ្រាវ និង កម្មសិក្សាក្រៅក្រប ខ័ណ្ឌវិនិយោគ ។

មាត្រា ១១ : អាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

ជំពូកទី៥

ទោសប្បញ្ញត្តិ

មាត្រា ១២ : ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់

ត្រូវបង្ខំអោយបង់ប្រាក់ពិន័យរដ្ឋបាល ៧.៥០០៛,០០ ក្នុងមួយថ្ងៃ សំរាប់ថ្ងៃដែលលើសបូកនឹងអាករលើការពន្យារទិដ្ឋាការរយៈពេល ១ ខែ (៧.៥០០៛ × ចំនួនថ្ងៃដែលលើស + ៧៥.០០០៛,០០) ។

មាត្រា ១៣ : ១–ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលស្នាក់នៅហួសរយៈពេលកំណត់លើសពី ៣០ ថ្ងៃ ត្រូវបង្ខំអោយបង់ប្រាក់ពិន័យដោយអនុលោមទៅតាមមាត្រា ១២ នៃអនុក្រឹត្យនេះ ហើយត្រូវបញ្ជាអោយចេញពីកម្ពុជាក្នុងរយៈពេល ៧ ថ្ងៃ ។

២–ក្នុងករណីរឹងរូស ឬ គេចវេសមិនចេញពីកម្ពុជាតាមកំណត់ដូចមានចែងក្នុងចំណុចទី ១ នៃមាត្រានេះសាមីខ្លួនត្រូវបង្ខំអោយបង់ប្រាក់ពិន័យទ្វេគុណ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

មាត្រា ១៤ : ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលល្មើសនឹងមាត្រា ៥ នៃអនុក្រឹត្យនេះ ហើយដែលសកម្មភាពផ្ទាល់បង្ហាញ ថាបានប្រើប្រាស់ទិដ្ឋាការខុសពីប្រភេទដែលបានស្នើសុំ ត្រូវពិន័យអន្តរការណ៍ ជាប្រាក់ ១២៥.០០០៛ ហើយត្រូវបណ្តេញចេញ អោយផុតពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៧ ថ្ងៃ បើពុំនោះត្រូវពិន័យទ្វេរ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពី អន្តោប្រវេសន៍ ។

មាត្រា ១៥ : ប្រាក់ពិន័យខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលប្រាក់ពិន័យនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

ជំពូកទី៦

ការហាមឃាត់ និង ការបដិសេធទិដ្ឋាការ

មាត្រា ១៦ : ទិដ្ឋាការគ្រប់ប្រភេទពុំអាចផ្តល់ទៅជនបរទេសមិនមែនអន្តោប្រវេសន្តដែល÷

១–មិនអាចចិញ្ចឹមខ្លួនឯង និងក្រុមគ្រួសារខ្លួន ហើយដែលគ្មានជនណាផ្សេង

សន្សារដោះស្រាយជំនួស ។

២–ប្រកបរបរពេស្យាចារ នាំភៀរអោយជនពេស្យាចារ ឬ ជំនួញពេស្យាកម្ម ផ្សេងៗទៀត។

៣–ពាក់ព័ន្ធនឹងជំនួញគ្រឿងញៀន ដោយខុសច្បាប់ ។

៤–ត្រូវកាត់ទោសពីការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក្នុងប្រទេសរបស់ខ្លួន ។

៥–ព្រះរាជាណាចក្រកម្ពុជា បានបណ្តេញចេញ ។

៦–បានលួចឡើងជិះនាវា ឬ យន្តហោះ

៧–ព្រះរាជាណាចក្រកម្ពុជា យល់ឃើញមិនចង់អោយមានវត្តមាននៅកម្ពុជា ។

៨–ស្វែងរកទិដ្ឋាការកម្ពុជា ដើម្បីគេចវេះពីច្បាប់នៃប្រទេសដើមរបស់ខ្លួន ។

មាត្រា ១៧ : រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អាចបដិសេធចោលនូវ ទិដ្ឋាការដែលបានផ្តល់អោយក្នុងសមត្ថកិច្ចរបស់ខ្លួនបានចំពោះមូលហេតុដូចខាងក្រោម ÷

១–ខ្ញាន់ទិដ្ឋាការបានរំលោភលើបទបញ្ញត្តិនានា នៃច្បាប់ស្តីពីអន្តោប្រវេសន៍ នៃព្រះរាជា ណាចក្រកម្ពុជា ។

២–ខ្ញាន់ទិដ្ឋាការត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ ។

៣–ទិដ្ឋាការដែលបានមកដោយការក្លែងបន្លំ ឬ កោសលុប ។

៤–រដ្ឋមន្ត្រីទាំងពីរ យល់ឃើញថាវត្តមានរបស់ខ្ញាន់ទិដ្ឋាការ អាចបង្កអោយមានគ្រោះថ្នាក់ ដល់សន្តិសុខជាតិ ។

ជំពូកទី៧

អវសានប្បញ្ញត្តិ

មាត្រា ១៨ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៩ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន

ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះ ហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

នរោត្តម រណប្ញទ្ធិ ហ៊ុន សែន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ២៩ អនក្រ.បក

ស្ដីពី

ថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ

បណ្ណស្នាក់នៅរយៈពេលខ្លី និង បណ្ណស្នាក់នៅអចិន្ត្រៃយ៍

សំរាប់ជនបរទេសអន្តោប្រវេសន្ត

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្ដិ ទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ

តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

សំរេច

មាត្រា ១ : អាករលើលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម :

ក-ឯកសារធ្វើដំណើរ ចំនួនបីសែនរៀល (៣០០.០០០៛,០០) ។

ខ-លិខិតបើកផ្លូវ ចំនួនប្រាំម៉ឺនរៀល (៥០.០០០៛,០០) ។

មាត្រា ២ : អាករលើការពន្យារលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម :

ក-ការពន្យាពេលឯកសារធ្វើដំណើ ចំនួនប្រាំម៉ឺនរៀល (៥០.០០០៛,០០)

ខ-ការពន្យារពេលលិខិតបើកផ្លូវ ចំនួនបីម៉ឺនប្រាំពីរពាន់ប្រាំរយរៀល (៣៧.៥០០៛,០០) ។

មាត្រា ៣ : កុមារទាំងពីរភេទមានអាយុ ១២ ឆ្នាំ ចុះ ដែលរួមដំណើរជាមួយឪពុក ម្តាយ ឬ អាណាព្យាបាល ត្រូវបានរួចអាករ ។

មាត្រា ៤ : អាករលើប័ណ្ណស្នាក់នៅត្រូវកំណត់ដូចខាងក្រោម :

ក-ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន (មានសុពលភាព ១ ឆ្នាំជាអតិបរិមា) ចំនួនពីរសែន ប្រាំម៉ឺនរៀល (២៥០.០០០៛,០០) ។

ខ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (មានសុពលភាព ២ ឆ្នាំ) ចំនួនប្រាំសែនរៀល (៥០០.០០០៛,០០) ។

គ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទុតិយតាចំនួនប្រាំសែនរៀល(៥០០.០០០៛,០០)។

មាត្រា ៥ : ថ្លៃអាករលើការពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ត្រូវកំណត់ចំនួនប្រាំសែនរៀល (៥០០.០០០៛,០០) ។

មាត្រា ៦ : ថ្លៃអាករគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។ បែបបទ នៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

មាត្រា ៧ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣០ អនក្រ.បក
ស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត - ១០៩៤ - ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត - ១០៩៤- ៩០ -៨៣ ចុះថ្ងៃ ទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស.រកត - ០១៩៦ - ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ ស្តីពីអន្តោប្រវេសន្ត ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រម នៃគណៈរដ្ឋមន្ត្រី

សំរេច

ជំពូកទី១

បទបញ្ញត្តិទូទៅ

មាត្រា ១ : ជនបរទេសអន្តោប្រវេសន្ត គឺជនបរទេសណាដែលបានកំណត់ក្នុងជំពូកទី៣ នៃច្បាប់ ស្តីពី អន្តោប្រវេសន៍ ។

មាត្រា ២ : អនុក្រឹត្យនេះកំណត់ពីបែបបទ សំរាប់ការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្ត ចេញ ចូល និងស្នាក់អាស្រ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ២

បែបបទក្នុងការសុំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣ : ជនបរទេសដែលមានបំណងមកស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាជនបរទេសអន្តោប្រវេសន្ត អាចដាក់ពាក្យសុំបានមកក្រសួងមហាផ្ទៃ តែតាមរយៈអាជ្ញាធរទូត ឬកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ឬតែតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងអោយផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេសដោយ ÷

១–ត្រូវបំពេញបែបបទ ទិដ្ឋាការ ។

២–ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចំលងលិខិតឆ្លងដែនរបស់ខ្លួន ឬ សេចក្តីចំលងឯកសារធ្វើ ដំណើរណាមួយដែលមានតម្លៃស្មើគ្នា ដែលមានសុពលភាពយ៉ាងតិច ៦ខែ មុនថ្ងៃចូល ព្រះរាជាណាចក្រកម្ពុជា ។

៣-ត្រូវមានរូបថតទំហំ ៤ × ៦ ចំនួន ៣សន្លឹក « ថតចំពីមុខ គ្មានពាក់មួក និងមិនពាក់វ៉ែន តា ពណ៌ ។

៤–ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាព ចំនួនមួយច្បាប់ ដែលចេញអោយដោយវេជ្ជបណ្ឌិត នៃប្រទេសដើមរបស់ខ្លួន ។ វិញ្ញាបនប័ត្រនេះត្រូវមានកាលបរិច្ឆេទ មិនហួសពី៣ខែ នៅពេលដាក់ពាក្យ ។

៥–ត្រូវមានភស្តុតាងបញ្ជាក់អំពីការមានមធ្យោបាយគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតផ្ទាល់ខ្លួន និង សមាជិកក្នុងបន្ទុកខ្លួនបាន និងមានអ្នកធានាក្នុងស្រុកដែលមានសមត្ថភាព និង លទ្ធភាពទទួលខុសត្រូវខាងជីវភាព និងមធ្យោបាយ ផ្គត់ផ្គង់ផ្សេងៗទៀត ។

៦–ត្រូវមានលិខិតថ្កោលទោស ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើម របស់ខ្លួន ។

៧–ត្រូវមានសេចក្តីចម្លងកិច្ចសន្យាការងារជាមួយឯកជន ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជាមួយច្បាប់ បើសិនជាមាន ។

៨–ត្រូវមានសលាកប័ត្រ ស្តីពីការតម្កល់ប្រាក់ធានាសំរាប់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់ទៅវិញ ឬមាតុភូមិនិវត្តន៍ ជាយថាហេតុចំពោះ ÷

ក–ជនបរទេសដែលមកពីប្រទេស ដែលមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រកម្ពុជា ចំនួន ប្រាំសែនរៀល (៥០០.០០០៛០០) ។

ខ–ជនបរទេស ដែលមកពីអាស៊ី និង អូសេអានី ចំនួន មួយលានពីរសែនប្រាំម៉ឺនរៀល (១.២៥០.០០០៛០០)

គ–ជនបរទេស ដែលមកពីមជ្ឈិមបូព៌ា និង អាហ្វ្រិក ចំនួន ពីរលានប្រាំសែនរៀល (២.៥០០.០០០ ៛០០)

ឃ–ជនបរទេស ដែលមកពីអឺរ៉ុប និង អាមេរិក ចំនួន បីលានប្រាំពីរសែនប្រាំម៉ឺនរៀល (៣.៧៥០.០០០ ៛០០)

ប្រាក់នេះត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ហើយអាចដកវិញបានលុះណាតែមានការ អនុញ្ញាតពីក្រសួងមហាផ្ទៃ ។

ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន អាយុតិចជាង ១៨ ឆ្នាំ មានបំណងស្នើសុំជាជនបរទេសអន្តោប្រវេសន្តអាចធ្វើពាក្យស្នើសុំនោះជាចង្កោមគ្រួសារ ។

ក្នុងករណីពាក្យស្នើសុំនោះបានទទួលការយល់ព្រម សាមីជនត្រូវបង់ថ្លៃអាករទិដ្ឋាការចំនួន ពីរសែនប្រាំម៉ឺនរៀល(២៥០.០០០៛០០)ក្នុងសមាជិកគ្រួសារម្នាក់ៗ លើកលែងតែកុមារអាយុ ១២ ឆ្នាំចុះ ត្រូវបង់ចំនួន មួយសែនពីរម៉ឺនប្រាំពាន់រៀល (១២៥.០០០៛០០) ក្នុងកុមារម្នាក់ៗ ។

មាត្រា ៤ : អនីតិជន សហព័ទ្ធដែលរួមរស់ជាមួយគ្នា និង អាស្រ័យពឹងពាក់គ្នាខាងផ្លូវកាយ និងខាងហិរញ្ញវត្ថុ ក្នុងលក្ខណៈជាសមាជិកគ្រួសារយ៉ាងជិតស្និទ្ធ ក៏អាចត្រូវទទួលបានការអនុញ្ញាតអោយធ្វើ អន្តោប្រវេសន្តបានដែរ នៅពេលដែល

ជនបរទេសអន្តោប្រវេសន្តណាមួយត្រូវបានទទួល ស្គាល់ហើយនោះ ។

មាត្រា ៥ : ការទទួលស្គាល់ជនបរទេសណាមួយជាជនអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

ជំពូកទី៣

ការស្នាក់នៅ ការងារ និង ការចេញ ចូល

មាត្រា ៦ : ជនបរទេសដែលត្រូវបានទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវសុំប័ណ្ណស្នាក់នៅ នៅការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរ បាលខេត្ត ក្រុង ក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីបានមកដល់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៧ : ជនបរទេសអន្តោប្រវេសន្ត ត្រូវសុំប័ណ្ណការងារតាមការកំណត់នៃច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៨ : ជនបរទេសអន្តោប្រវេសន្ត ដែលមានបំណងចាកចេញពី ព្រះរាជាណាចក្រកម្ពុជា ជាបណ្តោះ អាសន្នត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។ បែបបទនៃការស្នើសុំមានដូចតទៅ ÷

១- ត្រូវបំពេញពាក្យសុំចេញពីព្រះរាជាណាចក្រកម្ពុជា តាមរយៈស្នងការនគរបាលខេត្ត ក្រុង ។

២-ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចម្លងលិខិតឆ្លងដែនរបស់ខ្លួន ឬសេចក្តីចម្លងឯកសារធ្វើដំណើរ ។

៣-ត្រូវផ្តល់លិខិតថតចម្លងប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួនមួយច្បាប់ ។

៤- រូបថតទំហំ ៤ × ៦ មួយសន្លឹក « ថតចំពីមុខ គ្មានពាក់មួក និង វ៉ែនតាពណ៌ » ។

៥- ត្រូវបង់អាករទិដ្ឋាការចេញ - ចូល មួយលើកចំនួនប្រាំម៉ឺនរៀល (៥០.០០០៛០០)

កុមារមានអាយុ ១២ឆ្នាំចុះ ធ្វើដំណើរជាមួយឪពុក ម្តាយ ឬ អាណាព្យាបាលមិនចាំបាច់បំពេញ បែបបទដោយឡែកទេ តែត្រូវចុះឈ្មោះ និង បិទរូបថតជាមួយ ឪពុក ម្តាយ ឬអាណាព្យាបាល ។ កុមារជាអនីតិជនដែលធ្វើដំណើរទោលតែឯង ត្រូវបង្ហាញលិខិតអនុញ្ញាតិអោយចេញ ដែលចុះ ហត្ថលេខាដោយអាណាព្យាបាល ឬ ឪពុក ម្តាយស្រប ច្បាប់របស់គេ ។

មាត្រា ៩ : ជនបរទេសអន្តោប្រវេសន្ត ដែលបានបំពេញបែបបទដូចមានចែងក្នុងមាត្រា ៨ ខាងលើ អាចទទួលការបោះត្រា « អនុញ្ញាតអោយចេញ ចូលច្រើនដង » នៅលើលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរ ។ រយៈពេលនៃការអនុញ្ញាតអោយចេញ ចូលច្រើនដងនោះមិនត្រូវអោយលើសពីបីខែឡើយ ។

អាករទិដ្ឋាការ « អនុញ្ញាតអោយចេញ ចូលច្រើនដងត្រូវកំណត់ » ចំនួនបីសែនរៀល (៣០០.០០០ ៛០០) ។

មាត្រា ១០ : អាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ។ បែបបទនៃការប្រមូលអាករ នេះត្រូវ កំណត់ដោយប្រកាសអន្តរក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

ជំពូកទី៤

ការដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត

មាត្រា ១១ : អាចត្រូវដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលបានប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវតុលាការផ្តន្ទាទោសឧក្រិដ្ឋចាប់ពី៥ឆ្នាំឡើងទៅ ។

ជំពូកទី៥

អវសានបញ្ញត្តិ

មាត្រា ១២ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ៣១ អនក្រ.បក
ស្តីពីការប្តូរឈ្មោះ « សាកលវិទ្យាល័យភ្នំពេញ »
មកជា « សាកលវិទ្យាល័យភូមិន្ទភ្នំពេញ »

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៨៨ ស្តីពីការបង្កើត សាកលវិទ្យាល័យភ្នំពេញ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា ១ : អនុញ្ញាតអោយក្រសួងអប់រំយុវជន និងកីឡា ប្តូរឈ្មោះ « សាកលវិទ្យាល័យភ្នំពេញ » មកជា « សាកលវិទ្យាល័យភូមិន្ទភ្នំពេញ » វិញចាប់ពីឆ្នាំសិក្សា ១៩៩៥ - ៩៦ នេះតទៅ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថ លេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១១ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគធនធានសំរាប់ ជួយកសាងអាគារសិក្សា នៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ÷

១–លោក **ហ៊ិន ឌីខ** និង អ្នកស្រី **ស៊ុយ គួយ** បរិច្ចាគប្រាក់ ១៨.០០០ $US កសាងអាគារ ០២ ខ្នង ក្នុងសាលាបឋមសិក្សា កំពង់ហ្លួង ឃុំអង្គរបុរី ។

២-អ្នកស្រី **កែវ ម៉ារៀម** បរិច្ចាគប្រាក់ ១៧.០០០ $US កសាងអាគារ ០១ ខ្នង ក្នុងសាលាបឋមសិក្សា វិលក ឃុំបាស្រែ

៣-គណៈកម្មការសាងសង់វត្តវិលក កសាងអាគារសិក្សា ០១ខ្នង អស់ទឹកប្រាក់ ១២.០០០ $US ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១២ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនចំពោះសប្បុរសជនជប៉ុន ០២ រូប ដែលបានជួយកសាងអាគារសិក្សា ០៣ ខ្នង មាន ១៥ បន្ទប់ រួមមនឹងបរិក្ខារបង្រៀនគ្រប់ គ្រាន់ បង្គន់អនាម័យ សួនកុមារ និងអណ្តូងទឹកសំរាប់សាលា នៅក្នុងសាលា បឋមសិក្សាប្រាសាទ ស្រះកែវ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ អស់ទឹក ប្រាក់សរុប ៨២.០០០ $US ដូចមាននាមខាងក្រោម ÷

១–លោក **HIDEAKI NITANI** នាយកអង្គការ **JHP** នៅប្រទេសជប៉ុន ។

២–នាងកញ្ញា CHIEKO UCHIDA អ្នកសហការអង្គការ JHP នៅកម្ពុជា ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៣ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិតាមលំដាប់ថ្នាក់ ជូនចំពោះសប្បុរសជន ដែលបានបរិច្ចាគថវិកាចូលរួមកសាង សាលាបឋមសិក្សា ជើងធ្នុក ក្នុងឃុំ តាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ÷

ក–មេដាយមាស :

១–ស្ថានឯកអគ្គរាជទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ផ្តល់ថវិកា ៩៩.៣៥៦$US សំរាប់ទិញដីស្រែប្រជាជន និងសាងសង់អាគារសិក្សា ១៦បន្ទប់ ។

២–លោក **ម៉ា ឈឿន** និងអ្នកស្រី **អ៊ុក ម៉ាលី** បរិច្ចាគថវិកា ១៥.០០០$US

ខ–មេដាយប្រាក់ :

១–លោកឧកញ៉ា **សុខ គង់** និងលោកជំទាវ បរិច្ចាគថវិកា ៥.០០០ $US

គ–មេដាយសំរិទ្ធ :

១–លោកឧកញ៉ា **ស្រី លាងឃាង** និងលោកជំទាវ **ម៉ៅ ស៊ីម** ,បរិច្ចាគ ថវិកា ៤.២០០ $US

២–លោកឧកញ៉ា **លាវ ម៉េងឃីម** និងលោកជំទាវ **ជីង សុភាព** បរិច្ចាគ ថវិកា ៤.០០០ $US

៣–លោកឧកញ៉ា **គង់ ទ្រីវ** និងលោកជំទាវ បរិច្ចាគថវិកា ៣.០០០ $US

៤–លោកស្រី **សោម សុផល** បរិច្ចាគថវិកា ៣.០០០ $US

៥–លោក **ង៉ែ ហុកឈួន** អ្នកស្រី **អ៊ុង ស៊ីស្រ៊ន**បរិច្ចាគថវិកា ២.០០០ $US

៦–លោក **ម៉ក់ គីមហុង** បរិច្ចាគថវិកា ២.០០០ $US

៧–លោក **ចាន់ សារុន** បរិច្ចាគថវិកា ២.០០០ $US

៨–លោក **ង៉ាង ណាំ** និង អ្នកស្រី បរិច្ចាគថវិកា ២.០០០ $US

៩–លោក **សៀងណាំ** និងអ្នកស្រី **ទ៊ុន លី** បរិច្ចាគថវិកា ១.០០០ $US

១០-លោក **ខួន ឈឿន** និងអ្នកស្រី **សាត ណារី** បរិច្ចាគថវិកា ១.០០០ $US

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត កំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៤ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត.១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយាជាតិ** ជាអគ្គនាយករងទទួលបន្ទុកចំណូលជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ចរិយាជាតិ** ត្រូវទទួល អនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជា ណាចក្រកម្ពុជា

មាត្រា ១ : ត្រូវបានតែងតាំងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ទរ៉ាវាជាតិ** ជាអគ្គនាយករងទទួលបន្ទុកចំណូលជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងអ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ទរ៉ាវាជាតិ** ត្រូវទទួល អនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឬទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៥ អនក្រ.តត

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស.រកត.១០៩៥.០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជា ណាចក្រកម្ពុជា

- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយមាសស្ថាបនាជាតិ ជូនចំពោះលោកស្រី MARIKO OKAMURA ប្រធានអង្គការ ASAC ដែលបានជួយកសាង និងជួសជុលអាគារសិក្សា ព្រមទាំងបំពាក់សម្ភារឹមសិក្សាគ្រប់គ្រាន់ នៅក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ អស់ទឹកប្រាក់សរុបចំនួន ១២០.៣០០ $US ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង អប់រំយុវជននិងកីឡា និងអភិបាលខេត្ត កំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៦

អនុក្រឹត្យលេខ ១១៦ អនក្រ.តត
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួល សមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងមុខតំណែង ជូនចំពោះ ៖

លោក **គួច សាខន** ជាទីប្រឹក្សាផ្ទាល់ ឯកឧត្តម **អ៊ុង ផន** ទទួលបន្ទុកកិច្ចការសំរបសំរួល ជាមួយ កងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាមីខ្លួន ត្រូវ អនុវត្តន៍អនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២ - សេចក្ដីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

សេចក្ដីសំរេចលេខ ២២ សសរ.

ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយ

ប្រគល់បរិវេណប៉ូលីកឡាមកអោយធ្វើការជួសជុល

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- ផ្អែកតាមការចាំបាច់

សំរេច

ប្រការ ១ : ការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីដោះស្រាយប្រគល់បរិវេណប្ញទ្ធីកីឡាមកធ្វើការជួសជុល ដែលមានសមាសភាពដូចតទៅ ÷

១_ឯកឧត្តម **ហុក ឡុងឌី**	អគ្គនាយកនគរបាលជាតិ	ប្រធាន
២_ឯកឧត្តម **ពូ ដារ៉ានី**	អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
៣_ឯកឧត្តម **ខួន ម៉េងហ៊ាន**	អភិបាលរងរាជធានីភ្នំពេញ	អនុប្រធាន
៤_ឧត្តមសេនីយ៍ **ណុប ស៊ីណូ**	ប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃក្រសួងមហាផ្ទៃ	សមាជិក
៥_ឧត្តមសេនីយ៍ត្រី **លី យ៉ីម៉ុន**	ប្រធាននាយកដ្ឋានអធិការកិច្ចនៃ ក្រសួងការពារជាតិ	សមាជិក
៦_លោក **សូ សាមុត**	សមាជិកគណៈកម្មការជួសជុលប្ញទ្ធីកីឡា	សមាជិក
៧_លោក **សៀង ម៉េងស្រ៊ុន**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៨_លោក **សាម ម៉ុនហេង**	តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក

ប្រការ ២ : គណៈកម្មការនេះ មានភារកិច្ចដោះស្រាយប្រគល់បរិវេណព្រមទាំងអគារទាំងឡាយនៃ ប៉ូរីកីឡាទៅអោយគណៈកម្មការជួសជុលប៉ូរីកីឡាដើម្បីធ្វើការជួសជុលក្នុង ក្របខ័ណ្ឌជំនួយឧបត្ថម្ភរបស់ចិន ។

គណៈកម្មការនេះ ត្រូវធ្វើការងារដូចខាងក្រោមនេះ

- ស្រាវជ្រាវសង់ស្ថិតិប្រភេទអ្នកដែលរស់នៅក្នុងប៉ូរីកីឡា តាមអង្គភាព និងតាមដំណាក់កាលនៃវេលានីមួយៗ អោយបានពិតប្រាកដ
- ដោះស្រាយបញ្ហាសំណង់អនាធិតេយ្យ
- ដោះស្រាយបញ្ហាទីតាំងដែលជួលអោយទូរទូស្សន៍ប៉ុស្តិ៍លេខ ៥
- លើកគំរោងថវិកាសំរាប់ដោះស្រាយក្នុងកិច្ចការនេះ
- លើកវិធានការដោះស្រាយ និងសំណូមពរក្នុងកិច្ចប្រតិបត្តិការយកទីតាំងប៉ូរីកីឡាមកធ្វើការជួសជុលដើម្បី សុំយោបល់សំរេចពីរាជរដ្ឋាភិបាល
- ធ្វើរបាយការណ៍សរុបអំពីលទ្ធផលការងាររបស់គណៈកម្មការជូនរាជរដ្ឋាភិបាល

ប្រការ ៣ : គណៈកម្មការនេះ មានសិទ្ធិរៀបចំក្រុមការងារសំរាប់ប្រតិបត្តិក្នុងការប្រគល់ទីតាំងជាជំហាន ទៅអោយគណៈកម្មការជួសជុលប៉ូរីកីឡាអោយបានយ៉ាងឆាប់ទាន់ពេលវេលា ។

ប្រការ ៤ : សមាជិកគណៈកម្មការ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជននិងកីឡា ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ និងឯកឧត្តមអស់លោកដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

ប្រការ ៦ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៦

សេចក្តីសំរេចលេខ ២៣ សសរ

សេចក្តីសំរេច

ស្តីពីការប្រគល់ភារកិច្ចបណ្តោះអាសន្ន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមការស្នើសុំពីឯកឧត្តម **អ៊ុង ផន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច

សំរេច

ប្រការ ១ : ប្រគល់ភារកិច្ចជូនឯកឧត្តម **ណាឌី តាន** អគ្គលេខាធិការនៃរាជរដ្ឋាភិបាល អោយទទួលដឹកនាំ គ្រប់គ្រងការងារអធិការកិច្ច ជំនួសឯកឧត្តមទេសរដ្ឋមន្ត្រី **អ៊ុង ផន** ចាប់ពីថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៦ រហូតដល់ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៧ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់គ្រងក្រសួង រដ្ឋលេខាធិការអនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ណាឌី តាន់** ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និងត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

III - ការងារបណ្តាក្រសួង

១ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សារាចរ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

សារាចរលេខ ០១១ សរសហវ.ហ

ស្តីអំពីកិច្ចប្រតិបត្តិការចំណូលថវិការដ្ឋឆ្នាំ ១៩៩៦

កិច្ចប្រតិបត្តិការចំណូលថវិការដ្ឋកន្លងមក និង និយាយដោយឡែកចំណូលថវិការដ្ឋ៥ខែដើមឆ្នាំ ១៩៩៦ នេះ សុទ្ធតែត្រូវបានអនុវត្តដោយក្របខ័ណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំឆ្នាំ មានជាអាទិ៍

- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ អនុម័តដោយរដ្ឋសភានៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤ (ចាប់ពីមាត្រាទី ៦ ដល់មាត្រាទី ១២)
- សេចក្តីជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលេខ ០១៨សជណ.សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រង់ចំណុច (២_២)
- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ អនុម័តដោយរដ្ឋសភានៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៥
- ប្រកាសលេខ ០០៦ ប្រ.សហវ.ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥ ត្រង់ចំណុច (I_អំពីចំណូលថវិកា)
- អនុក្រឹត្យលេខ ៨២ អនក្រ. ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ ក្នុងភាគ III ជំពូកទី ១ ស្តីពីកិច្ចប្រតិបត្តិការចំណូល ។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦ អនុម័តដោយរដ្ឋសភានៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៥ ក្នុងភាគទី ១ ជំពូកទី ១ មាត្រា ១ និងមាត្រា ៦_១

- អនុក្រឹត្យលេខ ០៨ អនក្រ. ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- ប្រកាសលេខ ០១៤ ប្រ.សហវ.ថ. ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីការប្រគល់កាតព្វកិច្ចចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- សារាចរណែនាំលេខ ០០៧ សហវ.ម. ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីវិន័យថវិកា និងចលនាតំណាងត្រង់ចំណុច ៣ និង ចំណុច I-ខ-១៤

ទន្ទឹមនឹងនេះ ទោះបីមានការប្រឹងប្រែងអនុវត្តនូវកិច្ចប្រតិបត្តិការចំណូលក្នុងរំឡុង ៥ ខែដើមឆ្នាំ ១៩៩៦ ទទួលបានលទ្ធផលគួរអោយកត់សំគាល់ និយាយរួមគឺការប្រមូលធនធានក្នុងប្រទេស ដើម្បីបង់ចូលថវិការដ្ឋបានជាប្រចាំតាមកម្មវិធីគ្រោងទុកក៏ដោយ ក៏ក្នុងនេះនៅមានការខ្វះខាត និងចន្លោះនូវមុខសញ្ញាចំណូលខ្លះមិនទាន់បានបង់ រួមទាំងប្រភពចំណូលផ្សេងៗទៀតនៃផលទុននៃទ្រព្យសម្បត្តិរដ្ឋ ដែលជាប្រភពនៃការបាត់តុល្យភាពរវាងចំណូលនិងចំណាយថវិការដ្ឋគួរអោយបារម្ភ ។

បាតុភាពនិងការបាត់ចំណូល តាមការគត់សំគាល់ជារៀងរាល់ឆ្នាំ តែងតែកើតមានឡើងនៅដើមការិយបរិច្ឆេទនៃឆ្នាំថវិកានីមួយៗ ពិសេសចំណូលប្រក្រតីដែលស្ថិតក្នុងប្រភេទ II (ចំណូលមិនមែនសារពើពន្ធ) នៃបណ្តាលរោងចក្រសហគ្រាសរដ្ឋ ។

ដើម្បីអោយធនធានអចិន្ត្រៃយ៍របស់រដ្ឋ រួមមាន :

- ចំណូលប្រក្រតី (សង្កត់ធ្ងន់លើចំណូលប្រភេទ II)
- និងចំណូលជាមូលធន (និយាយដោយឡែកចំណូល ផ្តែក្នុងជាមូលធន) ដែលកំពុងស្ថិតនៅក្នុងផលិតផលសរុប នៃទ្រព្យសម្បត្តិរដ្ឋអាចប្រព្រឹត្តិទៅបាន ព្រមទាំងធានាបានចំណូលថេរ និងអចិន្ត្រៃយ៍ក្រោមអនុភាពនៃបទបញ្ញត្តិនិងច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងប្រចាំឆ្នាំដូចបានពោល

ខាងលើ ពិសេសសំរាប់ឆ្នាំ ១៩៨៦ នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរួមធ្វើការកំណត់នូវល័ក្ខខ័ណ្ឌនៃកិច្ចប្រតិបត្តិការ ចំណូលដូចខាងក្រោមនេះ ÷

I – ប្រភេទចំណូលថវិកាទូទៅរបស់រដ្ឋ

ប្រាក់ចំណូលប្រក្រតីទាំងអស់របស់រដ្ឋ និងប្រាក់ចំណូលជាមូលធន ត្រូវបាន ប្រមូលផ្តុំជា ៣ ប្រភេទ :

- ប្រភេទទី I : ពន្ធ និងអាករ
- ប្រភេទទី II : ចំណូលមិនមែនសារពើពន្ធ
- ប្រភេទទី III : ចំណូលជាមូលធន

និយាយដោយឡែកក្នុងនេះ គឺចំណូលប្រភេទទី II និង ប្រភេទ III

○ ចំណូលប្រភេទ II : ចំណូលមិនមែនសារពើពន្ធ

ចំណូលមិនមែនសារពើពន្ធ មានទំនាក់ទំនងជាសំខាន់ទៅនិងផលទុនលើទ្រព្យសម្បត្តិរដ្ឋ ដែលជាផលទុនបានមកពីសហគ្រាសសាធារណៈ កន្លែងបង់ថ្លៃខ្លះទៀតរបស់រដ្ឋ ព្រមទាំងប្រាក់ចំណូលមិនមែនសារពើពន្ធផ្សេងទៀតរួមមាន :

ជំពូក ២០ : ផលទុននៃទ្រព្យសម្បត្តិរដ្ឋ

- ផលនេសាទ
- ផលព្រៃឈើ
- ផលទុនបានមកពីសហគ្រាសសាធារណៈ
- កំរៃយកមុនក្នុងសម្បទាននៃទ្រព្យសម្បត្តិរដ្ឋ
- ពន្ធលើការកាន់កាប់កម្មសិទ្ធិសាធារណៈ
- ការជួលអចលនវត្ថុ
- ផលពីការលក់ផ្នែកគតយ
- ផលបានមកពីការលក់ទ្រព្យសម្បត្តិកំទេចកំទី........
- ផលពីការលក់ចលនវត្ថុខូចខាតរបស់រដ្ឋ
- ផលផ្សេងៗទៀតនៃទ្រព្យសម្បត្តិរដ្ឋ

ជំពូក ២១ : ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ

- ផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍
- ផលទុនវិទ្យុ ទូរទស្សន៍ និងការផ្សាយ
- ប្រាក់ចំណេញរតនាគារ និងការប្រាក់ផ្សេងៗ
- ចំណូលក្រៅសារពើពន្ធរបស់ខេត្តនានា
- ចំណូលផ្សេងៗទៀតក្រៅសារពើពន្ធ

✪ **ចំណូលប្រភេទទី III ចំណូលជាមូលធន**

ប្រាក់ចំណូលនេះចែកចេញជាបីជំពូក គឺប្រាក់ចំណូលក្នុងប្រទេសជាមូលធន (ជំពូក ៣០) អំណោយ (ជំពូក ៣១) និងជំនួយបានមកពីការខ្ចី (ជំពូក ៣២) ។

កិច្ចប្រតិបត្តិការជាសំខាន់ គឺសំដៅលើប្រាក់ចំណូលក្នុងប្រទេសជាមូលធន ដែលគប្បីគ្រប់ក្រសួង គ្រប់ស្ថាប័នរដ្ឋបាល និងបណ្តារោងចក្រសហគ្រាសរបស់រដ្ឋ ប្រមែប្រមូលចូលថវិកាជាតិមានជាអាទិ :

- ការលក់ទ្រព្យសម្បត្តិនៃទុនថេរ (អាគារ មធ្យោបាយដឹកជញ្ជូន បរិក្ខារនានា)
- ការលក់ដីធ្លី
- ការលក់ទ្រព្យសកម្មអរូបិយ ឬ ហិរញ្ញវត្ថុ
- ការសងប្រាក់ខ្ចី និងបុរេប្រទាន ដែលរដ្ឋបានយល់ព្រមដោយថវិកាចំពោះសហគ្រាសសាធារណៈ
- ចំណូលផ្សេងៗទៀត ក្នុងប្រទេសជាមូលធន..... ។ល។

II _ និតិបញ្ញត្តិនៃចំណូលថវិកា

និតិបញ្ញត្តិថវិកា និងសារាចរទាំងឡាយដែលបានប្រកាសអោយអនុវត្តសុទ្ធតែបានបង្ហាញ និងវិភាគយ៉ាងទូលំទូលាយនូវថវិការបស់រដ្ឋនិងថវិការបស់ស្ថាប័នសាធារណៈ ព្រមទាំងគោលការណ៍សំរាប់អនុវត្ត និង ការគ្រប់គ្រង

និតិបញ្ញត្តិថ្មីៗទាំងឡាយនោះ សុទ្ធតែមានគោលបំណងបញ្ជាក់ [illegible] អោយកាន់តែមានតម្លាភាពច្បាស់លាស់អំពីនីតិវិធីនៃចំណូលចំណាយ [illegible] ដែលត្រូវបានកំណត់យ៉ាងម៉ឺងម៉ាត់ដោយច្បាប់និងបទបញ្ជា ហើយទាមទារអោយមានការយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់បំផុតសំដៅធ្វើយ៉ាងណាអោយកិច្ចប្រតិបត្តិការចំណូលមាន[illegible]និងចំណាយ ។

បច្ចុប្បន្ននេះ បើទោះបីលទ្ធផលនៃកិច្ចប្រតិបត្តិការចំណូលពុំទាន់បានល្អប្រសើរនៅឡើយក្តី ក៏គ្រប់ក្រសួង គ្រប់ស្ថាប័នរដ្ឋបាលសាធារណៈក៏ដូចជាបណ្តាខេត្ត_ក្រុង គឺមានទំលាប់អនុវត្តការងារថវិកានេះរួចមកហើយ ។

ផ្អែកទៅតាមអនុក្រឹត្យលេខ ០៨ អនក្រ. ចុះថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ១៩៨៦ ស្តីពីការបែងចែក ចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៨៦ និងប្រកាសលេខ ០១៤ ប្រក. សហវ. ថ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ១៩៨៦ ស្តីពីការប្រគល់ភារកិច្ចចំណូលថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៨៦ រាល់កិច្ចប្រតិបត្តិការចំណូលត្រូវតែបន្តធ្វើការទូទាត់ និងប្រមែប្រមូលចំណូលអោយកាន់តែខ្លាំងក្លាទៅតាមច្បាប់ហិរញ្ញវត្ថុជាធរមាន។

ដូចនេះការប្រមែប្រមូលរាល់ប្រភេទចំណូលទូទៅរបស់រដ្ឋដូចមានចែងក្នុងចំណុច I គឺជាតួនាទីយ៉ាងសំខាន់ និងជាភារកិច្ចយ៉ាងទៀងទាត់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង គ្រប់ស្ថាប័នរដ្ឋបាលកណ្តាល និងអភិបាលគ្រប់ខេត្ត_ក្រុង សំដៅធានាតុល្យភាពជាគោលការណ៍ចំបង និងជាមូលដ្ឋានគ្រឹះថវិការដ្ឋ ។

បន្ទុកនៃការប្រមូលចំណូលនេះ មានហេតុផលសំខាន់ ៗ ដូចតទៅ :

១ /ភារកិច្ច :

_ប្រាក់ចំណូលសាធារណៈនានាត្រូវប្រមូលផ្តុំ និង ដាក់បញ្ចូលក្នុងរតនាគារជាតិទាំងអស់ដោយផ្ទាល់និងជាបន្ទាន់ ។

_ប្រាក់ចំណូលទាំងអស់គឺយកទៅសំរាប់ប្រើប្រាស់ទប់ទល់និងចំណាយទាំងអស់ ។

-កិច្ចប្រតិបត្តិការចំណូល ត្រូវកត់ត្រានិងចុះបញ្ជីអោយបានសមស្រប តាមមាតិកានៃថវិកា និងនៅរតនាគារ ។

-គ្រប់កិច្ចប្រមូលចំណូលទាំងអស់ទោះបានគ្រោងទុក ឬ មិនបានគ្រោងទុក ត្រូវបង់ចូលថវិការដ្ឋអោយបានទៀតទាត់តាមច្បាប់ និងបទបញ្ញត្តិជាធរមាន ។

២/ការហាមឃាត់ :

-ប្រាក់ចំណូលត្រូវកត់ត្រាចូលទាំងស្រុងមិនត្រូវទូទាត់ជាមួយចំណាយឡើង ។

-ហាមដាច់ខាតនូវការធ្វើកិច្ចប្រតិបត្តិការកាត់កងរវាងបំណុលត្រូវសង និង ប្រាក់ជំពាក់ត្រូវបង់ជូនរដ្ឋ ។ ធ្វើបៀបនេះនាំអោយមានការប្រឡូកប្របស់ប្រាក់ត្រូវសង និងប្រាក់ពន្ធត្រូវបង់ ឬ ប្រាក់ចំណូលផ្សេង ៗ ទៀត ដែលត្រូវផ្ទេរចូលថវិការដ្ឋ ។

-គ្មានការបោះបង់ចោលនូវប្រាក់ចំណូល ឬបំណុលណាមួយ... គ្មានការលើកលែងប្រាក់ពន្ធ និងអាករណាមួយ.... គ្មានការបន្ធូរបន្ថយបំណុលណាមួយអាចត្រូវបានសំរេច ឬ យល់ព្រមដោយគ្មានចែងក្នុងច្បាប់ និង បទបញ្ញាជាធរមានឡើយ ។

-ហាមកេងទុនថវិកាដើម្បីទុកប្រើប្រាស់ក្នុងប្រការផ្សេងៗហើយពន្យារពេលការបង់ចំណូលដែលបានចែងក្នុងច្បាប់ ឬរង់ចាំការបិទបញ្ជីគណនេយ្យប្រចាំឆ្នាំ ។

-ហាមរក្សាសមតុល្យគណនីចុងឆ្នាំ (31/12នៃឆ្នាំ) ក្នុងគោលបំណងជានាកិច្ចប្រតិបត្តិការ ចំណាយ(អាជីវកម្ម) នាដើមឆ្នាំ ឬ ទុកត្រៀមទ្រទ្រង់កម្មវិធីចំណូលថវិកាឆ្នាំថ្មី ។

III,វិន័យថវិកា

ថវិកាសំរាប់គ្រប់គ្រងប្រចាំឆ្នាំ សំខាន់ឆ្នាំ១៩៨៦នេះ គឺជាថវិកានៃការខិតខំប្រឹងប្រែងប្រមូលធនធានក្នុងប្រទេសអោយអស់លទ្ធភាព ដើម្បីបង់ជូន

រដ្ឋ ហើយបង្កើនឡើតក្នុងការចំណាយសំរាប់ការប្រព្រឹត្តទៅ នៃកិច្ចការរដ្ឋបាលសាធារណៈ ។

ក្នុងកិច្ចប្រតិបត្តិការចំណូល ៥ ខែ ដើម ១៩៩៦នេះ ប្រភពចំណូលក្នុងប្រទេសកំពង់ស្ថិតក្នុងស្ថានភាពមួយមានកំរិត ប៉ុន្តែទោះជាយ៉ាងនេះក្តីក៏នៅមានក្រសួង ស្ថាប័នរដ្ឋបាលសាធារណៈខ្លះដែលមានអង្គភាពអាជីវកម្មក្រោមឱវាទ បានខិតខំអនុវត្តវិន័យនៃការបង់ចំណូលជូនរដ្ឋបានទៀងទាត់ស្របច្បាប់និងបទបញ្ជាគួរអោយសរសើរ ។

ឯប្រការដែលគួរអោយសោកស្តាយ គឺនៅមានក្រសួង និងស្ថាប័នរដ្ឋបាលសាធារណៈខ្លះ ទោះបីបានយល់ពីស្ថានភាពថវិកាកំពុងជួបការលំបាកយ៉ាងណាក្តី ឬ ទោះបីបានទទួលលិខិតរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតពីទីស្តីការគណៈរដ្ឋមន្ត្រីអោយបង់ចំណូលចូលថវិការដ្ឋក៏ដោយ ក៏ពុំបានគិតដល់ផលប្រយោជន៍រួម ហើយនៅតែឆ្លៀតរកលេសពន្យារពេលបង់ចំណូលដដែល ព្រមទាំងបើកមុខចំណាយ ឯកចិត្ត ។

យោងតាមមាត្រា ៨ និង ១១ នៃច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ បានចែងច្បាប់ហើយថាគ្មានបទបញ្ញត្តិណាមួយទោះជាប្រភេទណាក៏ដោយ ឬ អនុសញ្ញាអន្តរជាតិណាមួយដែលអាចធ្វើអោយមានការប្រែប្រួល និងនាំមកនូវការបាត់ចំណូលដែលបានចែងក្នុងច្បាប់នោះឡើយ ។ ករណីបែបនេះអាចនឹងប្រព្រឹត្តិទៅបានលុះត្រាតែអនុវត្តតាមទំរង់ច្បាប់ និងបទបញ្ញាក្រោយពីមានយោបល់ឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ដូចនេះប្រាក់ចំណូលទាំងមូលរបស់រដ្ឋ គឺសំរាប់ប្រើប្រាស់ទប់ទល់នឹងការចំណាយទាំងអស់របស់រដ្ឋប៉ុន្តែប្រការដែលគួរអោយជៀសវាងមានជាអាទិ

- មិនអនុញ្ញាតអោយអាណាប័ក (ហាមដាច់ខាត) បង្កើនទឹកប្រាក់នៃឥណទានចំណាយដែលបាន អនុម័តក្នុងច្បាប់ថវិកាដោយសំអាងលើប្រាក់ចំណូល «ពិសេស » ណាមួយឡើយ ។

- ហាមដាច់ខាតមិនអោយយកប្រាក់ចំណូល «ផ្សេង ៗ» ដើម្បីបំពេញមុខចំណាយអោយខុសក្រៅលក្ខខណ្ឌដែលត្រូវកំណត់ដោយច្បាប់ ។

ជាគោលការណ៍ទូទៅ ឬ រាល់កិច្ចប្រតិបត្តិការចំណូលប្រចាំឆ្នាំត្រូវ និងតែប្រតិបត្តិអោយបានសំរេចតាមកម្មវិធីគ្រោងទុក ។

ប៉ុន្តែបើកិច្ចការ និងមុខទំនិញចំណូលនេះពុំបានសំរេច ឬ ពុំមិនគ្រប់តាមកម្មវិធីកំណត់ ដែលអោយខាតតុល្យភាពថវិកា នោះការប្រើប្រាស់ឥណទាននៃ [illegible] របស់បណ្តាក្រសួង ស្ថាប័នរដ្ឋបាលកណ្តាល និងរដ្ឋបាលខេត្ត ក្រុង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចាំបាច់អនុវត្តវិធានការខ្ទង់ចំណាយដូចមានចែងក្នុង មាត្រា៦ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៨៦ ។

វិធានការនេះ ពិតជានឹងអាចពង្រឹងនូវវិន័យថវិកា ព្រមទាំងផ្តល់នូវតម្លាភាពច្បាស់លាស់សំរាប់កំណត់ផ្លូវ និងមធ្យោបាយប្រមែប្រមូលប្រភពធនធានក្នុងប្រទេសបង់ជូនរដ្ឋកាន់តែមានប្រសិទ្ធភាព ។

បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នរដ្ឋបាលកណ្តាល ឬ គ្រប់ខេត្ត ក្រុង ក្រោយពីបានទទួលសារាចរនេះ បើមានការជួបការលំបាកដោយប្រការណាមួយជាថាហេតុ ត្រូវរួតរះពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរិះរកវិធីដោះស្រាយនិងណែនាំអនុវត្តអោយបានល្អព្រមទាំងឆ្លើយបញ្ជាក់ពីការទទួល បានសារាចរនេះ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៦

ប្រកាសលេខ ១៨៥ នបប្រក.សហវ

ស្តីពីការផ្ទេរតារកិច្ចគ្លាក់ទារគយ_រដ្ឋាករ

ដេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ ន.ស ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រម នស.រកម ០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ។
- បានឃើញសារាចរស្ដីពីការគ្រប់គ្រងមន្ត្រីរាជការគយ និងរដ្ឋាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០១ សហ.សហវ.គរ ចុះថ្ងៃទី០៦ ខែ មករា ឆ្នាំ ១៩៩៥ ។
- បានឃើញលិខិតស្នើសុំរបស់ទីចាត់គយ-រដ្ឋាករលេខ ៥៩៨/៩៦ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦ ។

សំរេច

ប្រការ ១ : ត្រូវបានធ្វើការផ្ទេរភារកិច្ចគយរដ្ឋាករ ចំនួន ២៥ នាក់ដូចខាងក្រោម ÷

១-លោក **ហ៊ុយ ស៊ីណេត** បច្ចុប្បន្នបុគ្គលិកសាខាគយនិងរដ្ឋាករ ខេត្តស្ទឹងត្រែង ផ្ទេរភារកិច្ច ទៅជាបុគ្គលិកការិយាល័យគយ និងរដ្ឋាករផែស្ងួត ។

២–លោក ង៉ុយ ម៉ុន្នី បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ ពុំក្រឡ (ខេត្តស្ទឹងត្រែង) ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

៣–លោក គុជ សុខា បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ អូរស្វាយខេត្ត (ស្ទឹងត្រែង) ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យនិងរដ្ឋាករផែស្ងួត ។

៤–លោក ខេង សុផល បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ អូរយ៉ាដាវ(ខេត្ត រតនៈគិរី) ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

៥–លោក ឆេត រាជ បច្ចុប្បន្នជា ភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ អូរាំង ដាក់ដាំ (ខេត្តមណ្ឌលគិរី) ផ្ទេរភារកិច្ច ជាបុគ្គលិកការិយាល័យគយ និងរដ្ឋាករផែស្ងួត

៦–លោក កែវ ស៊ីន បច្ចុប្បន្នភ្នាក់ងារស្នាក់ការគយ និងរដ្ឋាករ ដា (ខេត្តកំពង់ចាម) ផ្ទេរភារកិច្ចទៅជាបុគ្គលិក ការិយល័យគយនិងរដ្ឋាករផែស្ងួត ។

៧–លោក សាំង ណាន បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ មេមត់(ខេត្តកំពង់ចាម)ផ្ទេរភារកិច្ចជាបុគ្គលិក ការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

៨–លោក គន់ ស៊ីដារ៉ា បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករ ជ័យឃ្លាំង(ខេត្តក្រចេះ)ផ្ទេរភារកិច្ចទៅជា បុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត ។

៩–លោក គីម ឧត្ដី បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករវ៉ាលិ (ខេត្តក្រចេះ)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយា ល័យគយនិងរដ្ឋាករផែស្ងួត ។

១០–លោក **ឈុប គឹមសាន** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករផ្លូវ
កែងស្នួល(ខេត្ត ក្រចេះ) ផ្ទេរភារកិច្ចទៅជា
បុគ្គលិកការិយាល័យនិងរដ្ឋាករផែស្ងួត ។

១១–លោក **ឈួន សំឡេង** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករបឹង
ត្រកួន (ខេត្តបន្ទាយមានជ័យ)ផ្ទេរភារកិច្ចទៅ
ជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផែស្ងួត

១២–លោក **ឱម ឧត្តម** បច្ចុប្បន្នជាភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករអូ
ស្មាច់(ខេត្តបន្ទាយមានជ័យ)ផ្ទេរភារកិច្ចទៅជា
បុគ្គលិកការិយាល័យគយនិងដ្ឋាករផែស្ងួត ។

១៣–លោក **សោម សុមនា** បច្ចុប្បន្នជាភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករ
ថ្មស (ខេត្តកោះកុង) ផ្ទេរភារកិច្ចទៅជា
បុគ្គលិកិរិយាល័យគយនិង រដ្ឋាករផែស្ងួត ។

១៤–លោក **អន ស៊ីនួន** បច្ចុប្បន្នជាភាក់ងារ ស្នាក់ការគយនិងរដ្ឋាករ
ត្រពាំងល្ងៅ(ខេត្ត កំពត) ផ្ទេរភារកិច្ចទៅជា
បុគ្គលិកការិយាល័យនិងរដ្ឋាករផែស្ងួត ។

១៥–លោក **ហុក លីសេង** បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយនិងរដ្ឋាករភ្នំ
ឫស្សី (ខេត្តពោធិសាត់)ផ្ទេរភារកិច្ចទៅជាបុគ្គ
លិកការិយាល័យគយនិងររដ្ឋាករផែស្ងួត ។

១៦–លោក **ច្រឹក ចំនួណា** បច្ចុប្បន្នជាបុគ្គលិកការិយាល័យបុគ្គលិក ផ្ទេរ
ភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋា
ករផែស្ងួត ។

១៧–លោក **ស្រេង សំណាង** បច្ចុប្បន្ន បុគ្គលិក ការិយាល័យ វិវាទនិង
ច្បាប់ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យ
គយនិងរដ្ឋាករផែស្ងួត ។

១៨–លោក **សុខ យឿន**	បច្ចុប្បន្នជាបុគ្គលិក ការិយាល័យ គណនេយ្យ ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
១៩–លោក **ឌុច សុផល**	បច្ចុប្បន្ន បុគ្គលិកការិយាល័យបុគ្គលិកផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
២០–លោក **នួន សុផល**	បច្ចុប្បន្នភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករទឹរូម ខេត្តកំពត(ខេត្តកំពត) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
២១–លោក **ជា តូក**	បច្ចុប្បន្ន ភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករទាន់ហាន់(ខេត្តកំពត)ផ្ទេរភារ កិច្ចជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
២២–លោក **ម៉ក់ សាម៉ុឌី**	បច្ចុប្បន្ន ភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករលកព្រែកចាក(ខេត្តកំពត) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
២៣–លោក **ជួម ចំរើន**	បច្ចុប្បន្នភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករអូរយ៉ាដាវ(ខេត្តរតនៈគីរី) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
២៤–លោក **គាំង លាង**	បច្ចុប្បន្នជាភ្នាក់ងារស្នាក់ការគយ និង រដ្ឋាករអូរយ៉ាដាវ (ខេត្តរតនគីរី) ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករផៃស្លូត ។
២៥–លោក **ឌូ វណ្ណា**	បច្ចុប្បន្នភ្នាក់ងារ ស្នាក់ការគយនិងរដ្ឋាករប៉ោយប៉ែត(ខេត្តបន្ទាយមានជ័យ)ផ្ទេរភារកិច្ចទៅជាបុគ្គលិកការិយាល័យគយនិងរដ្ឋាករ

ផែស្ទួត។

ប្រការ ២ : សាមីខ្លួនត្រូវមានវត្តមានតាមទីកន្លែងបំពេញភារកិច្ចក្នុងប្រការ ១ យ៉ាងយូរ ១៥ ថ្ងៃ ក្រោយ ទទួលលិខិតបង្គាប់ការ បើហួសការកំណត់នេះ ត្រូវបានចាត់ទុកថា បោះបង់ចោលការងារ ។

ប្រការ ៣ : លោកអគ្គនាយក នាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិកទីចាត់ការតយ-រដ្ឋាករនិងសាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃ ចុះហត្ថលេខាលេខាតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ៣៩៨ ឧក.ប្រក

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅ ក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/៩៥ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ។

- បានឃើញលិខិត ០៤៧/៩៦ គ.វិ.ក ចុះថ្ងៃទី ១១-៧-១៩៩៦ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញលិខិតលេខ ៩០៦ភព .សណ ចុះថ្ងៃទី ២៤–០២–៩៦ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយសាងសង់អាគារផលិតកម្មកាត់ដេរសំលៀកបំពាក់
- យោងពាក្យស្នើរបស់ក្រុមហ៊ុនយូណាយធីត ហ្គាកមិន ហ្វាក់តូរីកូអិលធីឌីចុះថ្ងៃទី ២៣-៥-៩៦

សំរេច

ប្រការ ១ : អនុញ្ញាតអោយក្រុមហ៊ុន យូណាយធីត ហ្គាកមិន ហ្វាគរី កូអិលធីឌី (UNITED FAITH GA RMENT FACTORYCO LTD) តំណាងដោយ លោក ខូវ សម្បត្តិ ជនជាតិខ្មែរ ភេទប្រុសអាយុ ៣៧ ឆ្នាំ អាស័យដ្ឋាន ផ្ទះលេខ ២៧ ផ្លូវព្រះសុរាម្រិត សង្កាត់ចតុមុខ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញកាន់អត្តសញ្ញាណប័ណ្ណ លេខ 319963 ភព ចុះថ្ងៃទី ២៤–៩–៩១ បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញដែលមានឈ្មោះថា រោងចក្រកាត់ដេរសំលៀកបំពាក់យូណាយធីតហ្វេត មានទីតាំងនៅផ្លូវ ២១៨_២៣០ សង្កាត់ទឹកល្អក់ទី ៣ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរ សំលៀកបំពាក់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិដ្ឋាន និងគុណភាព ផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែជូនក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល អំពីស្ថានភាព ផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះ ត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផល " សំលៀក

បំពាក់ "តាមគំរូ ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ពូ សុធីរៈ

* * *

៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ០០២៩/៩៦ កព.ប្រក

ស្តីពីការបង្កើតក្រុមបញ្ជូនឯកសាររបស់ក្រុមការងារពិសេស

ប្រធានក្រុមការងារពិសេស

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសេចក្តីសំរេចលេខ ៨៧ សសរ.ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារពិសេស សំរាប់ធ្វើការវាយបក ឆ្លើយតបចំពោះការផ្សាយ ពត៌មានបង្ខូចពីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមតម្រូវការនិងភារកិច្ចចាំបាច់ ។

សំរេច

ប្រការ ១ : បង្កើតក្រុមបញ្ជូនឯកសាររបស់ក្រុមការងារពិសេស ដែលមានសមាសភាព :

១_ឯកឧត្តម **ព្រាប ញាណវិចិត្រ** អនុរដ្ឋលេខាធិការនៃក្រសួងពត៌មាន ប្រធាន

២_លោក **ឡេង សុជា** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងពត៌មាន អនុប្រធាន

៣_លោក **ម៉ុត មុទុត** អគ្គនាយករង អា. កា. ប៉េ នៃក្រសួងពត៌មាន សមាជិកអចិន្ត្រៃយ៍

៤_លោក **មួង សុទត្តិ** ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន សមាជិក

៥_លោក **ជុក សារុំ** ប្រធានការិយាល័យទីស្តីការក្រសួងពត៌មាន សមាជិក

ប្រការ ២ : ក្រុមបញ្ជូនឯកសារ របស់ក្រុមការងារពិសេសនេះមានភារកិច្ច :

- បញ្ជូនឯកសាររាជរដ្ឋាភិបាលទៅគ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុងក្នុងប្រទេស
- បញ្ជូនឯកសារ រាជរដ្ឋាភិបាលទៅបណ្តាស្ថានទូត ស្ថានបេសកកម្មការទូត អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅក្រៅប្រទេស ។

ប្រការ ៣ : ថវិកាចំណាយរាល់ការរៀបចំ និងបញ្ជូនឯកសារ គឺបន្ទុកចំណាយរបស់ក្រុមការងារពិសេស ។

ប្រការ ៤ : សមាជិកក្រុមការងារពិសេស ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រុមការងារពិសេស និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានក្រុមការងារពិសេស

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៦៦/៩៦ ពម.បលប្រក
ស្តីពី ការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពតិមាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នសរកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងតាមការចំបាច់របស់ក្រសួង ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការក្រសួងពតិមាន ចំនួន ០១នាក់ ជាថ្នាក់អនុប្រធាននាយកដ្ឋាន ដូចមាននាមខាងក្រោមនេះ :

១_លោក **ខិក សមប្រាថ្នា** ជាអនុប្រធាននាយកដ្ឋានរដ្ឋបាល ទទួលបន្ទុកលេខាធិការដ្ឋាន

ប្រការ ២ : លោកអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លោកអគ្គនាយក បណ្តាអគ្គ-នាយកដ្ឋាន ចំណុះ លោកប្រធាននាយកដ្ឋានបាល បុគ្គលិក និង លោកក្នុង

ប្រការ ១ : មានការអនុវត្តតាមប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៦៧/៩៦ ពម.បលប្រក

ស្តីពី ការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នសរកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងតាមការចំបាច់របស់ក្រសួង ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបស់មន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្ត្រីរាជការក្រសួងពតិមាន ចំនួន ០១នាក់ ជាថ្នាក់អនុប្រធាននាយកដ្ឋាន ដូចមាន នាមខាងក្រោមនេះ :

១_លោក **អៀង ធុន្ធា** ជាអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ និង ពិធីការ

ប្រការ ២ : លោកអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លោកអគ្គនាយក បណ្ដាអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានរដ្ឋបាលបុគ្គលិក និង លោកក្នុងប្រការ១ មានភារៈអនុវត្តតាមប្រកាសចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៦៨/៩៦ ពម.បលប្រក
ស្តីពី ការតែងតាំងមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នសរកម ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពតិមាន
- យោងតាមការចាំបាច់របស់ក្រសួង ។
- ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពរបសមន្ត្រីរាជការ

សំរេច

ប្រការ ១ : តែងតាំងមន្រ្តីរាជការក្រសួងពត៌មាន ចំនួន ០២នាក់ ជាថ្នាក់អនុប្រធាននាយកដ្ឋាន ដូចមាន នាមខាងក្រោមនេះ :

១_លោក **ជា សុខេន** ជាអនុប្រធាននាយកដ្ឋានទទួលបន្ទុកទូរបច្ចុប្បន្នភាពនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ

២–លោក **គាត វណ្ណៈ** ជាអនុប្រធាននាយករដ្ឋានទទួលបន្ទុកកម្មវិធីនៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិ

ប្រការ ២ : លោកអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ លោកអគ្គនាយក បណ្តាអគ្គ-នាយកដ្ឋានចំណុះលោកប្រធាននាយកដ្ឋានបាលរដ្ឋបុគ្គលិក និង អស់លោកក្នុងប្រការ ១ មានភារៈអនុវត្តតាមប្រកាស ចាប់ ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រដ្ឋមន្រ្តី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩៦

ប្រកាសលេខ ១៧៨/៩៦ ពម.បលប្រក

អនុញ្ញាតជូនលោក យ៉ាង យ៉ុងជាយ សញ្ជាតិកូរ៉េខាងត្បូង

ជាប្រធានក្រុមហ៊ុន KORECAM IMEX CO LTD

បើកការិយាល័យប្រព័ន្ធផ្សព្វផ្សាយកូរ៉េ

រដ្ឋមន្ត្រីក្រសួងពត៌មាន

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ជំពូក ៣ មាត្រាទី ៤១

– បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

– បានឃើញច្បាប់ស្តីពីរបប សារពត៌មាន នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើប្រាស់ តាមព្រះរាជក្រមលេខ នស.រកម ០៨៩៥–០៧ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ។

– បានឃើញសំណើសុំបើកការិយាល័យ ប្រព័ន្ធផ្សព្វផ្សាយកូរ៉េ ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ១៩៩៦។

– បានឃើញការចាំបាច់ ដើម្បីផ្សព្វផ្សាយដល់ ប្រជារាស្ត្រ និងវិនិយោគទុនកូរ៉េ ។

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក យ៉ាំង យ៉ុងដាយ «Mr. BAYON ,YOUNG DAL » សញ្ជាតិ កូរ៉េខាងត្បូង ជាប្រធានក្រុមហ៊ុន KORECAM IMEX CO.LTD បើកការិយាល័យប្រព័ន្ធផ្សព្វផ្សាយ កូរ៉េ នៅរាជធានីភ្នំពេញ « KOREA MEDIA OFFICE IN PHNOM PENH » ដែលមាន ទីស្នាក់ការតាំងនៅផ្ទះលេខ ១៧២ អឺ០ ផ្លូវលេខ ១២៨ សង្កាត់មិត្តភាព ខ័ណ្ឌ ៧ មករា រាជធានីភ្នំពេញ ។

ប្រការ ២ : រាល់សេវាកម្មប្រព័ន្ធផ្សព្វផ្សាយកូរ៉េ ដែលត្រៀមចូលមកសំពេញទស្សនៈកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ត្រូវគោរពនូវទំនៀមទំលាប់ប្រពៃណី និងច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ការិយាល័យប្រព័ន្ធផ្សព្វផ្សាយកូរ៉េនេះ ត្រូវសហការជិតស្និទ្ធ និងទទួលការណែនាំផ្ទាល់ពី នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មាន ដើម្បីដំណើការសកម្មភាពផ្លាស់ប្តូរការផ្សព្វផ្សាយពត៌មានទៅវិញទៅមក ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នាយកដ្ឋានមណ្ឌលពត៌មាន និងលោកប្រធានក្រុមហ៊ុន KORECAM IMEX CO.LTD. ត្រូវអនុវត្តនូវ

ប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះមានប្រសិទ្ធភាព ២ ឆ្នាំ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
អៀង មូលី

* * *

បោះពុម្ពនៅរោងពុម្ពធីត៍

លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១០៨០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

***

ឆ្នាំទី ៤ លេខ ២៤ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៦

រាជកិច្ច

រួមមាន

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្ដាហ៍